ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣៦..អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រ នៃបេឡាជាតិសន្តិសុខសង្គម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ២៣៦ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៣៩ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម។

ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម សរសេរជាអក្សរកាត់ថា **ក.ឥ.ប.ស**.។

ជំពូកទី២
តួនាទីនិងភារកិច្ចរបស់ ក.ឥ.ប.ស.

មាត្រា២ .-

ក.ឥ.ប.ស. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យនិងតាមដានការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**.
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពសេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**.
- ពិនិត្យនិងផ្តល់យោបល់ជូន **ប.ស.ស**. លើតម្រូវការចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជនដែលស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**. ដើម្បីធានាឱ្យបាននូវសេវាសុខាភិបាលគ្រប់គ្រាន់នៅក្នុងតំបន់
- ពិនិត្យនិងសម្រេចលើការកំណត់ស្ថានភាពកូនពិការឬជំងឺរ៉ាំរ៉ៃរបស់ធនលាភឧត្តរជីវី និងសោធនឧត្តរជីវីដែលបញ្ជាក់ដោយគ្រូពេទ្យឯកទេស
- សម្រេចអំពីការកំណត់ស្ថានភាពទុព្វលភាពរបស់សមាជិក **ប.ស.ស**.
- សម្រេចអំពីលក្ខខណ្ឌឬស្ថានភាពដែលតម្រូវឱ្យមានអ្នកថែរក្សាសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍និងសោធនទុព្វលភាព
- ពិនិត្យនិងសម្រេចលើការកំណត់អត្រានៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍របស់សមាជិក **ប.ស.ស**. ដែលទទួលរងហានិភ័យការងារដែលមិនមានចែងក្នុងតារាងកំណត់អត្រានៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តាមសំណើរបស់គ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស**.
- ពិនិត្យនិងផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ

- ពិនិត្យនិងផ្តល់យោបល់លើការរៀបចំការកែសម្រួលតារាងកំណត់អត្រានៃការបាត់បង់សមត្ថភាពការងារ អចិន្ត្រៃយ៍សម្រាប់ផ្នែកហានិភ័យការងារ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ **ក.ទ.ប.ស.** ប្រចាំខែ ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូនអគ្គនាយក **ប.ស.ស.**
- អនុវត្តការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក **ប.ស.ស.**។

ជំពូកទី៣
សមាសភាពរបស់ ក.ទ.ប.ស.

មាត្រា៣ .-

ក.ទ.ប.ស. មានសមាសភាពដូចខាងក្រោម៖

- តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប	ប្រធាន
- តំណាងក្រសួងសុខាភិបាល ១រូប	អនុប្រធាន
- ឥស្សរជនមានបទពិសោធពាក់ព័ន្ធនឹងវិជ្ជាជីវៈវេជ្ជសាស្ត្រ ៥រូប	សមាជិក
- ឥស្សរជនមានបទពិសោធពាក់ព័ន្ធនឹងសុវត្ថិភាពនិងសុខភាពការងារ ២រូប	សមាជិក
- អ្នកឯកទេសខាងសេដ្ឋកិច្ចសុខាភិបាល ឬហិរញ្ញប្បទានសុខាភិបាល ឬធានារ៉ាប់រងសុខភាព ឬសុខភាពសាធារណៈ ២រូប	សមាជិក
- តំណាងនិយោជក ១រូប	សមាជិក
- តំណាងកម្មករនិយោជិត ១រូប	សមាជិក
- តំណាងនាយកដ្ឋានសុវត្ថិភាព និងសុខភាពការងារ ១រូប	សមាជិក
- តំណាងបេឡាជាតិសន្តិសុខសង្គម ១រូប	សមាជិក។

សមាសភាពជាក់ស្តែងនៃ **ក.ទ.ប.ស.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៤ .-

សមាសភាពនៃ **ក.ទ.ប.ស.** ត្រូវមានលក្ខណសម្បត្តិ និងបទពិសោធដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្រពាក់ព័ន្ធនឹងវិជ្ជាជីវៈសុខាភិបាល ឬសេដ្ឋកិច្ចសុខាភិបាល ឬហិរញ្ញប្បទានសុខាភិបាល ឬធានារ៉ាប់រងសុខភាព ឬសុខភាពសាធារណៈ ឬសញ្ញាបត្រសមមូលផ្សេងទៀត។ ដោយឡែក ប្រធាន និងអនុប្រធាន ត្រូវមានបរិញ្ញាបត្រជាន់ខ្ពស់ពាក់ព័ន្ធនឹងវិជ្ជាជីវៈវេជ្ជសាស្ត្រ សេដ្ឋកិច្ច ឬសញ្ញាបត្រសមមូលផ្សេងទៀត
- មានបទពិសោធការងារយ៉ាងតិច ១០(ដប់)ឆ្នាំ
- មានព្រឹត្តិបត្រប្តេជ្ញាលទោសដែលបញ្ជាក់ថាពុំធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋ។

បេក្ខភាពឥស្សរជនជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលចំនួន៥(ប្រាំ)រូប ដែលមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ត្រូវស្នើដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

បេក្ខភាពឥស្សរជនដែលមានវិជ្ជាជីវៈខាងសុវត្ថិភាពនិងសុខភាពការងារចំនួន២(ពីរ)រូប ដែលមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ត្រូវស្នើដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

បេក្ខភាពអ្នកឯកទេសដែលមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ត្រូវស្នើឡើងដោយអគ្គនាយក **ប.ស.ស.** ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

មាត្រា៥ .-

សមាសភាពនៃ **ក.ទ.ប.ស.** មានអាណត្តិ ៣(បី)ឆ្នាំ។

សមាសភាពនៃ **ក.ទ.ប.ស**. អាចត្រូវបានបញ្ចប់មុនអាណត្តិក្នុងករណីដែលបុគ្គលនោះ៖

- បាត់បង់ភាពជាតំណាងក្រសួង ស្ថាប័ន
- ទទួលមរណភាព
- សុំលាឈប់ជាលាយលក្ខណ៍អក្សរ
- បាត់បង់សម្បទាវិជ្ជាជីវៈ ឬវិបល្លាសស្មារតី ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬ
- មានព្រឹត្តិបត្រប្រកាសទោសដែលបញ្ជាក់ថាត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

សមាសភាពដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរស្របតាមលក្ខខណ្ឌខាងលើ មានអាណត្តិត្រឹមរយៈពេលដែលនៅសល់។

ជំពូកទី៤
ការប្រព្រឹត្តទៅរបស់ **ក.ទ.ប.ស**.

មាត្រា៦ .-

ក.ទ.ប.ស. មានរបបប្រជុំសាមញ្ញប្រចាំត្រីមាសតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញ។

នៅពេលប្រធាន **ក.ទ.ប.ស**. អវត្តមានឬមានធុរៈចាំបាច់ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានដឹកនាំប្រជុំជំនួស។

កិច្ចប្រជុំ **ក.ទ.ប.ស**. អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ភាគរយ នៃចំនួនសមាជិកសរុប។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាវេជ្ជសាស្ត្រមានឧត្តមានុភាព។

មាត្រា៧ .-

នាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាលនៃ **ប.ស.ស**. ជាលេខាធិការដ្ឋាននៃ **ក.ទ.ប.ស**.។ ប្រធាននាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាលនៃ **ប.ស.ស**. ជាប្រធានលេខាធិការដ្ឋាននៃ **ក.ទ.ប.ស**.។

មាត្រា៨ .-

ក្នុងករណីចាំបាច់ **ក.ទ.ប.ស**. អាចអញ្ជើញគ្រូពេទ្យជំនាញ ឬវេជ្ជបណ្ឌិតឯកទេស ឬឥស្សរជន ឬអ្នកជំនាញឯកទេសផ្សេងទៀតដើម្បីផ្តល់យោបល់លើកិច្ចការរបស់ខ្លួនបាន បន្ទាប់ពីមានការឯកភាពពីអគ្គនាយក **ប.ស.ស**.។

មាត្រា៩ .-

របៀបរបបការងាររបស់ **ក.ទ.ប.ស**. និងលេខាធិការដ្ឋាននៃ **ក.ទ.ប.ស**. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ក.ទ.ប.ស**.។

មាត្រា១០ .-

ការចំណាយសម្រាប់អនុវត្តភារកិច្ចរបស់ **ក.ទ.ប.ស**. គឺជាបន្ទុករបស់ **ប.ស.ស**. ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**. អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា១១ .-

ក.ទ.ប.ស. មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ **ប.ស.ស**. ដើម្បីដំណើរការការងាររបស់ខ្លួន។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

មាត្រា១២ .-

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹង **ក.ទ.ប.ស**. ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១៣ .-

អនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា១៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០២៦

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រី
ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ហោ សុរ

រដ្ឋមន្ត្រី
ក្រសួងសុខាភិបាល

សាស្ត្រាចារ្យ **ឈាង រ៉ា**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ